# មេរៀនទី៦៧៖ ព្រះយេស៊ូវបណ្តេញអ្នកលក់ដូរចេញពីព្រះវិហារ

## យ៉ូហាន ២៖១៣-២២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/NYLfSy6D9E0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/Z3a6nSZuK3k

**គោលបំណង៖** ព្រះចង់ឲ្យយើងថ្វាយបង្គំទ្រង់ដោយស្មោះត្រង់។

**ខគម្ពីរចងចាំ៖ យ៉ូហាន ៤៖២៤** *"ឯព្រះទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់នោះ ត្រូវតែថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិតដែរ "*។

**ចំរៀង** ( *យូធូបលីង* )៖

១. ពេលដែលព្រះវិញ្ញាណបរិសុទ្ធ https://youtu.be/RODHIMCRzw4

២. ស្តេចលើស្តេច https://youtu.be/CPBqHYVwm3M

៣. ខ្ញុំថ្វាយបង្គំទ្រង់ https://youtu.be/1C4guXZFdAw

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «បែកហើយ»

សម្ភារៈដែលត្រូវការ៖ ប៉េងប៉ោង សម្រាប់កុមារម្នាក់១



១. ឲ្យប៉េងប៉ោងទៅកុមារម្នាក់១ ហើយឲ្យពួកគេផ្លុំ រួចចងវា។

២. ប្រាប់កុមារថា ប៉េងប៉ោងនេះសំខាន់ណាស់សំរាប់ពួកគេ ដូច្នេះពួកគេត្រូវការពារវាឲ្យបានល្អ។

៣. តើពួកគេនឹងមានអារម្មណ៍យ៉ាងដូចម្តេចប្រសិនបើប៉េងប៉ោងនេះបែក?

៤. ឲ្យកុមារក្រោកឡើងទាំងអស់គ្នា ប្រាប់ពួកគេឲ្យព្យាយាមធ្វើឲ្យប៉េងប៉ោងរបស់កុមារដទៃបែក ហើយក្នុងពេលតែមួយនោះ ពួកគេត្រូវការពារប៉េងប៉ោងរបស់ខ្លួនកុំឲ្យកុមារផ្សេងធ្វើបំបែកវាបានឲ្យសោះ។ ( កុមារអាចអោបប៉េងប៉ោង ឬគ្រូអាចជ្រើសរើសឲ្យ កុមារចងប៉េងប៉ោងនៅកដៃ ឬក៏កជើងក៏បាន )

៥. ទុកពេលឲ្យពួកគេ ១នាទី

៦. សួរទៅកុមារដែលប៉េងប៉ោងរបស់គេត្រូវបានបំបែកថា គេមានអារម្មណ៍យ៉ាងម៉េចដែរ ពេលដែលប៉េង-ប៉ោង របស់ខ្លួនបានបែកដូច្នោះ។

### ៤. ការណែនាំមេរៀន

សូមគិតពីអ្វីដែលមានសារៈសំខាន់សម្រាប់អ្នក។ វាអាចជារបស់លេងដែលអ្នកចូលចិត្ត ខោអាវ ស្បែកជើង ឬកន្លែងដែលអ្នកចូលចិត្តជាដើម។ ចុះបើអ្វីមួយ ដែលអ្នកយកចិត្តទុកដាក់បានខូច? ចុះបើម្តាយយើងបានបោះរបស់លេងយើងចោល? ឬបើសិនប្អូនប្រុសប្អូនស្រីរបស់អ្នក ធ្វើឲ្យសម្លៀកបំពាក់ដែលអ្នក

ស្រឡាញ់ខូចវិញ? ឬ បើសិននរណាម្នាក់យកសំរាមកមកពង្រាយនៅកន្លែងដែលអ្នកចូលចិត្តវិញ? តើអ្នកនឹងមានអារម្មណ៍ដូចម្តេច? ថ្ងៃនេះយើងនឹងរៀនពីព្រះហឫទ័យរបស់ព្រះយេស៊ូវ នៅពេលទ្រង់ឃើញព្រះវិហារជាកន្លែងដែលទ្រង់សព្វព្រះទ័យក្លាយទៅជាកន្លែងលក់ដូរទៅវិញ ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

មានមនុស្សជាច្រើនបានធ្វើដំណើរពីចំងាយមកព្រះវិហារ។ ជាធម្មតាព្រះវិហារគឺសំបូរមនុស្សណាស់! មិនត្រឹមតែសំបូរមនុស្សទេ តែក៏សំបូរសត្វច្រើនទៀតផង។ មានសត្វជាច្រើននៅក្នុងព្រះវិហារ ហេតុអ្វីបានជាត្រូវមានសត្វនៅក្នុងព្រះវិហារបែបនេះ? ពីព្រោះវាស្រ្តរបស់ព្រះបានធ្វើយញ្ញបូជាសត្វនៅក្នុងព្រះវិហារដើម្បីទូលសូមការអត់ទោសចំពោះអំពើបាបរបស់គេ។ មានមនុស្សជាច្រើនបានធ្វើដំណើរពីចំងាយមកព្រះវិហារដើម្បីធ្វើយញ្ញបូជានៅព្រះវិហារ ហើយវាមានការលំបាកក្នុងការនាំយកសត្វមកជាមួយ ដើម្បីធ្វើយញ្ញបូជា ដូច្នេះហើយបានជា មានគេដាក់លក់ចៀម និងព្រាបនៅក្នុងព្រះវិហារ។

ថ្ងៃមួយព្រះយេស៊ូវបានធ្វើដំណើរមកព្រះវិហារ ប៉ុន្តែព្រះអង្គបានឃើញអ្នកលក់យកប្រាក់ជាច្រើនពីមនុស្សដែលមកធ្វើយញ្ញបូជានោះ។ អ្នកលក់ទាំងនោះបានបង្ខំឲ្យប្រជាជនក្រីក្រចំណាយលុយច្រើន ដូច្នេះហើយទើបគេអាចថ្វាយបង្គំព្រះជាមួយនឹងដង្វាយបូជារបស់ពួកគេបាន។ អ្វីដែលពួកគេធ្វើគឺមិនត្រឹមត្រូវទេ! នេះមិនមែនជាអ្វីដែលអ្នកត្រូវធ្វើនៅក្នុងព្រះវិហារទេ ហើយនេះមិនមែនជាអ្វីដែលអ្នកត្រូវធ្វើសំរាប់ថ្វាយយញ្ញបូជាទៅព្រះឡើយ។

ទ្រង់បានប្រាប់ទៅមនុស្សទាំងអស់នោះថា ជំនួសឲ្យការថ្វាយបង្គំព្រះពួកគេបានរំលោភបំពាន និងប្រើប្រាស់ដំណាក់របស់ព្រះក្នុងផ្លូវខុស។ ព្រះអង្គមានបន្ទូលទៅគេថា "ចូរយករបស់ទាំងនេះចេញទៅ កុំឲ្យយកដំណាក់នៃព្រះវរបិតាខ្ញុំ ធ្វើជាផ្ទះជំនួញឡើយ!" នោះទ្រង់ក៏យកខ្សែធ្វើជារំពាត់ ដេញគេចេញពីព្រះវិហារទាំងអស់ទៅ គឺដេញទាំងចៀម ទាំងគោ ហើយក៏ចាក់ប្រាក់របស់ពួកអ្នកលក់ដូរចេញដែរ ព្រមទាំងផ្កាប់តុគេផង។ មែនហើយ មនុស្សមួយចំនួននៅទីនោះមិនសប្បាយចិត្តទេ ដោយសារព្រះយេស៊ូវកំពុងរំខានដល់មុខរបររកស៊ីរបស់ពួកគេ។ តើព្រះយេស៊ូវជានរណា? ហេតុអ្វីបានជាការគិតរបស់ទ្រង់សំខាន់? ហើយតើអ្នកគិតថា ហេតុអ្វីបានជាការនេះសំខាន់សម្រាប់ព្រះយេស៊ូវ?

ព្រះយេស៊ូវជ្រាបច្បាស់ជាងគេអំពីអំណាច និងសារៈសំខាន់នៃគ្រឿងយញ្ញបូជា។ ទ្រង់ត្រៀមនឹងក្លាយជាអ្នក លះបង់ខ្លួនឯងនៅលើឈើឆ្កាង ហើយទ្រង់មិនចង់ឱ្យការលះបង់របស់ទ្រង់គ្មានន័យដូច ការលក់ដូរនៅទីផ្សារនោះទេ។ ប្រសិនបើពួកគេឃើញការលះបង់របស់ទ្រង់នៅលើឈើឆ្កាងគ្រាន់តែជាវិធីមួយផ្សេងទៀត ដើម្បីរកលុយ ឬការស្នើសុំការអត់ទោសដោយមិនយកចិត្តទុកដាក់ នោះពួកគេនឹងមិនអាចចូលទៅនគរស្ថានសួគ៌ ហើយរស់នៅជាមួយព្រះបានទេ។ ព្រះយេស៊ូវចង់ឲ្យការបូជាលះបង់របស់ទ្រង់លើឈើឆ្កាង មានន័យច្រើនជាងនេះ! នេះជាវិធីតែមួយគត់ដែលមនុស្សទាំងនេះនឹងអាចរស់នៅស្ថានសួគ៌ជាមួយទ្រង់បាន។

អ្វីដែលសំខាន់បំផុតចំពោះព្រះយេស៊ូវនោះគឺ ថ្ងៃមួយយើងនឹងរស់នៅឯនគរស្ថានសួគ៌ជាមួយនឹងទ្រង់។ ហើយដើម្បីធ្វើបែបនោះបាន យើងត្រូវទទួលយកនូវការលះបង់របស់ទ្រង់នៅលើឈើឆ្កាង ដែលបានអត់ទោសចំពោះអំពើបាបរបស់យើង។ នេះគឺជាអំណោយដោយឥតគិតថ្លៃ ហើយយើងទាំងអស់គ្នាត្រូវតែ

ទទួលយកវា។ ហើយដោយសារតែអំណោយឥតគិតថ្លៃនេះ យើងថ្វាយបង្គំទ្រង់ដោយចិត្តស្មោះត្រង់ដោយព្រលឹងវិញ្ញាណ និងសេចក្តីពិត។

## ៦. សំនួរពិភាក្សា

១. តើមនុស្សកំពុងធ្វើអ្វីក្នុងព្រះវិហារដែលធ្វើឲ្យព្រះយេស៊ូវខ្ញាល់?

*(អ្នកលក់បានលក់សត្វក្នុងតម្លៃខ្ពស់ ដើម្បីរកប្រាក់ជំនួសឱ្យការជួយមនុស្សឲ្យថ្វាយបង្គំព្រះ)*

២. តើព្រះយេស៊ូវបានធ្វើអ្វី?

*(ព្រះយេស៊ូវបានយករំពាត់មកវាយដេញសត្វ ព្រមទាំងផ្កាប់តុប្រាក់របស់ ពួក អ្នកលក់ដូរចេញដែរ)*

៣. ហេតុអ្វីបានជាយើងគួរតែថ្វាយបង្គំព្រះ?

*(ដោយសារទ្រង់បានប្រទានអំណោយទាននៃសេចក្តីស ង្គ្រោះ ដល់ យើងដោយសេចក្តីជំនឿ)*

## ៧. ល្បែងកំសាន្ត «សម្អាតដំណាក់ព្រះជាមួយគ្នា»

សម្ភារៈដែលត្រូវការ៖ អំបោស និងក្រដាសឆ្នូលចូលគ្នា



១. ចែកកុមារជា២ក្រុម ហើយឲ្យកុមារពាក់កណ្តាលនៃក្រុមនីមួយៗឈរនៅម្ខាងម្នាក់ក្នុងថ្នាក់រៀន។

២. ឲ្យអំបោស និងក្រដាសឆ្នូលរួចទៅក្រុមនីមួយៗ

៣. កុមារម្នាក់ៗត្រូវបោសក្រដាសដែលឆ្នូរនោះ ទៅកាន់សមាជិកក្រុមរបស់ ពួកគេដែលនៅឈរចាំនៅជ្រុងម្ខាងទៀតក្នុងថ្នាក់រៀន។ នៅពេលដែលកុមារនៅចាំជ្រុងម្ខាងក្នុងបន្ទប់ទទួលបានអំបោស និងក្រដាសឆ្នូលនោះហើយ ពួកគេត្រូវបន្តលេងល្បែងនេះរហូតដល់ កុមារទាំងអស់បានលេងគ្រប់ៗគ្នា។

៤. ក្រុមដែលធ្វើចប់មុនគេនឹងឈ្នះល្បែងនេះ។ ពន្យល់កុមារថា ព្រះវិហារជាដំណាក់របស់ព្រះ ដូច្នេះ ត្រូវតែរក្សាព្រះវិហារឲ្យបានស្អាត ឲ្យដូចដែលពួកគេមកព្រះវិហារដោយចិត្តបរិសុទ្ធដែរ។

## ៨. ខគម្ពីរចងចាំ

**យ៉ូហាន ៤៖២៤** *"ឯព្រះ ទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះ ត្រូវតែថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិតដែរ "*។

## ៩. ហាត្ថកម្ម

សូមផាត់ពណ៌ "ព្រះយេស៊ូវបណ្តេញអ្នកលក់ដូរចេញពីព្រះវិហារ" ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ពេលខ្លះយើងមកព្រះវិហារដោយមិនបានចាំថាតើយើងមកថ្វាយបង្គំនរណា? មានមនុស្សមួយចំនួនទៅព្រះវិហារដើម្បីជួបមិត្តភក្តិរបស់គេ ឬទៅព្រះវិហារដើម្បីប្រកបគ្នា។ យើងត្រូវចាំថាព្រះគឺសាកសមនឹងទទួលការថ្វាយបង្គំពីយើង ពីព្រោះព្រះអង្គបានបញ្ជូនព្រះយេស៊ូវមកសុគតនៅកន្លែងរបស់យើង ដូច្នេះហើយយើងអាចនឹងចូលទៅឯនគរស្ថានសួគ៌ ដើម្បីរស់នៅជាមួយទ្រង់អស់កល្បជានិច្ច។ សូមពិចារណាពីអាកប្បកិរិយាពេលដែលអ្នកទៅព្រះវិហារ។ ទូលសុំឲ្យព្រះកែប្រែចិត្តរបស់អ្នកដូច្នេះ ហើយអ្នកអាចថ្វាយបង្គំព្រះដោយព្រលឹងវិញ្ញាណ និងសេចក្តីពិត ហើយត្រូវធ្វើជាគំរូល្អសំរាប់កុមារៗផងដែរ។

# ព្រះយេស៊ូវបណ្តេញអ្នកលក់ដូរចេញពីព្រះវិហារ



សូមសរសេរខគម្ពីរចងចាំ៖ ____________________

____________________

____________________

____________________